# ពិពិធកម្មសេដ្ឋកិច្ចជនបទ និងការអភិវឌ្ឍ “ភូមិគំរូ”

បទបង្ហាញដោយ ÷ លោក **អឿន ឆារិទ្ធ** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

រាជធានីភ្នំពេញ ថ្ងៃទី ២០-២១ ខែកុម្ភៈ ឆ្នាំ២០២៥

# មាតិកា


១. សេចក្តីផ្តើម

២. សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ ២០២៤

៣. បញ្ហា និងការប្រឈម

៤. វិធានការដោះស្រាយ

៥. មេរៀន និងបទពិសោធន៍

   ៥.១. ចំណុចខ្លាំង

   ៥.២. ចំណុចខ្វះខាត

   ៥.៣. សំណូមពរ

៦. ទិសដៅការងារបន្ត

៧. សន្និដ្ឋាន

# ១. សេចក្តីផ្តើម

## ១.២. និន្នាការនៃពិពិធកម្មសេដ្ឋកិច្ចជនបទនៅកម្ពុជា

- ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ សំដៅលើដំណើរការកែលម្អលក្ខខណ្ឌសេដ្ឋកិច្ច និងគុណភាពរស់នៅរបស់ប្រជាជនជនបទ ដោយផ្តោតលើការបង្កើតប្រភពប្រាក់ចំណូលចម្រុះ បង្កើតឱកាសការងារ/មុខរបរ ការកសាងសហគមន៍ប្រកបដោយភាពធន់ និងនិរន្តរភាព។ ការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដោះស្រាយតម្រូវការ និងបញ្ហាប្រឈមរបស់ប្រជាជននៅតាមជនបទ តាមរយៈការអភិវឌ្ឍកសិកម្មជាលក្ខណៈគ្រួសារ ការបង្កើតការងារមិនមែនកសិកម្ម រួមមានសិប្បកម្ម សេវាកម្ម និងទេសចរណ៍។
- ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ សំដៅលើបណ្តុំសកម្មភាពសេដ្ឋកិច្ច ផលិតផល និងសេវាកម្មដែលមាននៅក្នុងតំបន់ជនបទ និងមានគោលដៅ
  - កាត់បន្ថយការពឹងផ្អែកលើមុខរបរឬការងារតែមួយមុខ ដូចជាកសិកម្មជាដើម ដើម្បីបង្កើតសេដ្ឋកិច្ចជនបទរឹងមាំ និងនិរន្តរភាព
  - កាត់បន្ថយភាពក្រីក្រ បង្កើនកម្រិតជីវភាពរស់នៅ បង្កើតភាពធន់នឹងវិបត្តិសេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុ ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងមាននិរន្តរភាព
  - ធ្វើឱ្យមានកំណើនសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទប្រកដោយនិរន្តរភាព ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ប្រជាជននៅតំបន់ជនបទប្រកដោយភាពសម្បូរបែប នឹងមានសុខុដុមនីយកម្ម
  - ផ្តល់ចំណេះដឹង ជំនាញ និងបំណិនជីវិត ដើម្បីបង្កើតឱកាសការងារសមរម្យ មុខរបរនៅមូលដ្ឋានកាត់បន្ថយនិងកាត់បន្ថយការធ្វើចំណាកស្រុក

# ១. សេចក្តីផ្តើម

## ១.២. ទិដ្ឋភាពទូទៅនៃពិពិធកម្មសេដ្ឋកិច្ចជនបទនៅកម្ពុជា

❖ គន្លឹះសំខាន់ៗនៃធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទនៅកម្ពុជារួមមាន÷

- ការធ្វើពិពិធកម្មកសិកម្មចម្រុះ និងបង្កើនតម្លៃបន្ថែម÷ ការលើកទឹកចិត្តឱ្យមានការធ្វើពិពិធកម្មលើសពីដំណាំប្រពៃណី ដូចជាស្រូវ កាត់បន្ថយការពឹងផ្អែកលើដំណាំទោល ការចិញ្ចឹមសត្វ ការបង្កើនតម្លៃបន្ថែម ការចងក្រងនិងពង្រឹងសហគមន៍កសិករ ដើម្បីប្រមូលផ្តុំធនធានសហគមន៍ និងធ្វើឱ្យប្រសើរឡើងនូវអំណាចចរចាទីផ្សារ
- ការបង្កើតមុខរបរក្រៅពីកសិកម្ម÷គាំទ្រ និងលើកទឹកចិត្តដល់ការបង្កើតមុខរបរបន្ថែមក្រៅពីកសិកម្មដូចជា សិប្បកម្មប្រពៃណី តម្បាញ គ្រឿងស្មូន និងចម្លាក់ផ្សេងៗ បណ្តុះគោលគំនិតសហគ្រិនភាពសង្គម លើកទឹកចិត្តដល់ការពង្រឹងសិប្បកម្មគ្រួសា អាជីវកម្មដែលប្រើប្រាស់ធនធានក្នុងសហគមន៍ និងការផ្សារភ្ជាប់ទីផ្សារ
- ការអភិវឌ្ឍជំនាញ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ÷ បង្កើតឱកាសការងារ និងមុខរបរចម្រុះនៅតាមជនបទ តាមរយៈបណ្តុះបណ្តាលជំនាញមូលដ្ឋាន បំណិនជីវិត និងវិជ្ជាជីវៈជាពិសេសដល់យុវជន

# ១. សេចក្តីផ្តើម

## ១.២. និន្នាការទូទៅនៃពិពិធកម្មសេដ្ឋកិច្ចជនបទនៅកម្ពុជា

❖ គន្លឹះសំខាន់ៗនៃពិពិធកម្មសេដ្ឋកិច្ចជនបទនៅកម្ពុជារួមមាន÷

- ការគាំទ្រផ្នែកមីក្រូហិរញ្ញវត្ថុ÷ ការប្រើប្រាស់ និងទទួលបានមីក្រូហិរញ្ញវត្ថុត្រឹមត្រូវ ដោយយកចិត្តទុកដាក់លើការផ្តល់ឥណទានសហគមន៍ និងការចងក្រងក្រុមសន្សំ ហើយផ្តោតអាទិភាពឥណទានមិនមែនសាច់ប្រាក់ សម្រាប់ជួយដោះស្រាយតម្រូវការផ្សេងៗ ឬការបង្កើនប្រាក់ចំណូលគ្រួសារដែលងាយរងគ្រោះ តាមរយៈការបង្កើតធនាគារស្រូវ អង្ករ ធនាគារជី ឥណទានសត្វ......។ល។
- ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងទេសចរណ៍សហគមន៍÷ គាំទ្រ និងលើកទឹកចិត្តបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិ ដោយទាញយកប្រយោជន៍ពីទេសភាពធម្មជាតិ និងសម្បត្តិបេតិកភណ្ឌវប្បធម៌ក្នុងតំបន់សម្រាប់កំណើនសេដ្ឋកិច្ច
- ការដាក់បញ្ចូលកម្មវិធីឌីជីថល÷ គាំទ្រ ជំរុញ និងលើកទឹកចិត្តឱ្យប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីភ្ជាប់អ្នកផលិតនៅតាមជនបទជាមួយនឹងទីផ្សារ

➢ មុខរបរសំខាន់ៗ សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជនបទ រួមមាន÷

- **វិស័យកសិកម្ម÷**ការងារដាំដុះ ការងារចិញ្ចឹមសត្វ និងវារីវប្បកម្ម
- **ការងារ និងមុខរបរមិនមែនកសិកម្ម ÷** សិប្បកម្ម សេវាកម្ម សំណង់ និងការងាររដ្ឋបាល

# ១. សេចក្តីផ្តើម

## ១.២. ទិដ្ឋភាពទូទៅនៃការអភិវឌ្ឍ "ភូមិគំរូ" របស់ក្រសួងអភិវឌ្ឍន៍ជនបទ

- លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅឱ្យប្រសើរឡើងប្រកបដោយ បរិយាបន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- លើកកម្ពស់សង្គម និងវប្បធម៌ តាមរយៈការអប់រំ ការលើកកម្ពស់ក្រមសីលធម៌ សុជីវធម៌នៃការរស់នៅ ចេះគោរពឱ្យតម្លៃគ្នា ដើម្បីកសាងសហគមន៍ដែលមាន "វប្បធម៌គ្រួសារល្អ វប្បធម៌នៃការគោរពឱនលំទោន និងវប្បធម៌នៃភាពស៊ីវិល័យ"
- បង្កើនការចូលរួមរបស់សហគមន៍ តាមរយៈការពង្រឹងសមត្ថភាពដឹកនាំការអភិវឌ្ឍ និងបណ្តុះផ្នត់គំនិតភាពជាម្ចាស់លើការងារបង្កើនសេដ្ឋកិច្ចគ្រួសារ និងចូលរួមសកម្មភាពអភិវឌ្ឍន៍ភូមិដ្ឋាន
- លើកកម្ពស់ និងថែរក្សាវប្បធម៌ប្រពៃណីដូនតា ជាពិសេសគាំទ្រការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច

# លក្ខណៈសម្បត្តិចំនួន៥នៃ ភូមិគំរូ
## នៅតំបន់ជនបទក្នុងព្រះរាជាណាចក្រកម្ពុជា




> ភូមិគំរូសំដៅដល់ "ភូមិដ្ឋានដែលមានសុខុដុមនីយកម្ម និងការចូលរួមរបស់ប្រជាជនក្នុងភាពជាម្ចាស់ ធានាបាននូវចរន្តសេដ្ឋកិច្ច និងនិរន្តរភាពកំណើនប្រាក់ចំណូលគ្រួសារ, ទទួលបានប្រសិទ្ធភាពនៃសេវាសង្គមកិច្ច, មានសុខភាព និងបរិស្ថានរស់នៅល្អ, ហេដ្ឋារចនាសម្ព័ន្ធសមស្រប និងអភិបាលកិច្ចល្អ"។

ប្រភព៖ ប្រការ៣នៃប្រកាសស្តីពីការកំណត់លក្ខណៈសម្បត្តិ "ភូមិគំរូ" របស់ក្រសួងអភិវឌ្ឍន៍ជនបទ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២៤ ដោយឯកឧត្តម ឆាយ ឫទ្ធិសែន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

**១. សេដ្ឋកិច្ច**

សំដៅដល់លក្ខខណ្ឌដែលប្រជាពលរដ្ឋនៅក្នុងភូមិទទួលបានប្រាក់ចំណូលប្រចាំខែរបស់គ្រួសារ, ការងារ និងកម្លាំងពលកម្ម, ការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ, សំណង់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្នុងភូមិ និងមធ្យោបាយប្រើប្រាស់ផលិតកម្ម និងទ្រព្យសម្បត្តិ។

**២. សង្គម និងវប្បធម៌**

សំដៅដល់លក្ខខណ្ឌដែលប្រជាពលរដ្ឋនៅក្នុងភូមិទទួលបានកម្រិតអប់រំមូលដ្ឋានរបស់កុមារ និងយុវជន, ជំនាញមូលដ្ឋាន និងបំណិនជីវិត, ស្មារតីសមូហភាព និងសាមគ្គីភាពក្នុងសហគមន៍, វប្បធម៌និងប្រពៃណីដូនតា, និងការចូលរួមរបស់ស្ត្រីនិងជនមានពិការភាព។

**៣. សុខភាព និងបរិស្ថានរស់នៅ**

សំដៅដល់លក្ខខណ្ឌដែលប្រជាពលរដ្ឋនៅក្នុងភូមិទទួលបានសេវាទឹកស្អាត, សេវាអនាម័យ, សេវាសុខភាពមូលដ្ឋាន, ការអភិវឌ្ឍបៃតងក្នុងភូមិ, និងការគ្រប់គ្រង និងទុកដាក់កាកសំណល់ផ្សេងៗ។

**៤. ហេដ្ឋារចនាសម្ព័ន្ធ**

សំដៅដល់លក្ខខណ្ឌដែលប្រជាពលរដ្ឋនៅក្នុងភូមិទទួលបានការអភិវឌ្ឍផ្លូវក្នុងភូមិ, ការផ្គត់ផ្គង់អគ្គិសនី, ការស្រោចស្រព ឬដាំដុះគ្រប់រដូវកាល, ការកសាងសំណង់អគារសាធារណៈរបស់ភូមិ, និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

**៥. អភិបាលកិច្ច**

សំដៅដល់លក្ខខណ្ឌដែលប្រជាពលរដ្ឋនៅក្នុងភូមិទទួលបានការដឹកនាំ និងសម្របសម្រួលការងារអភិវឌ្ឍន៍ភូមិ, ការរៀបចំផែនការអភិវឌ្ឍន៍ភូមិ, ការចងក្រងនិងផ្តើតសហគមន៍មូលដ្ឋាន, សេវាសាធារណៈ, និងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។




ឯកឧត្តម ឆាយ ឫទ្ធិសែន
រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

# ២. សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ ២០២៤

## ២.១ ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ

- រៀបចំសិក្ខាសាលាដើម្បីការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ ព្រមទាំងជំរុញបង្កើតការងារ និងមុខរបរនៅជនបទ ចំនួន ២១លើក មានអ្នកចូលរួមសរុប ៩២០នាក់ ស្រី ៥២៧នាក់
- ចុះតាំងពិព័រណ៍ពាណិជ្ជកម្មផលិតផលជនបទ និងសហគមន៍ ចំនួន ១លើក នៅខេត្តកំពត
- បណ្តុះបណ្តាលដើម្បីការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ ចំនួន ១៩វគ្គ មានអ្នកចូលរួមសរុប ៣៩៧នាក់ ស្រី ២៥៦នាក់
- មានឥណទានសរុបមានចំនួន ២ ៣២៥ ៤២៧ ៣១២.៦៥ រៀល (ពីរប៊ីលាន បីរយម្ភៃប្រាំលាន បួនរយម្ភៃប្រាំពីរពាន់ បីរយដប់ពីររៀល និងហុកសិបប្រាំសេន ) មានអ្នកខ្ចីសរុប ៤៨៥នាក់ ស្រីចំនួន ៣៣១នាក់ នៅភូមិគោលដៅចំនួន ៧៨ភូមិ ៤៣ឃុំ ២២ស្រុក ក្នុងខេត្តគោលដៅ ចំនួន ៩។

# កម្រងរូបភាពសកម្មភាពការអភិវឌ្ឍសេដ្ឋកិច្ចជនបទ













# កម្រងរូបភាពសកម្មភាពការអភិវឌ្ឍសេដ្ឋកិច្ចជនបទ

















# ២. សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ ២០២៤

## ខ. ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព

- ពង្រឹងសមត្ថភាពមន្ត្រី តាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាក្នុងប្រទេសចំនួន ៥៩៦លើក មានមន្ត្រីចូលរួមសរុប ៥ ០៥១នាក់ (ស្ត្រី ១ ២០១នាក់) និងក្រៅប្រទេសចំនួន ១៦លើក មន្ត្រីចូលរួមសរុប ៥២នាក់ ស្ត្រី ១៦នាក់

- បណ្តុះបណ្តាលជំនាញមូលដ្ឋានដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តគោលដៅចំនួន ១១ខេត្ត រួមមាន ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាលបានចំនួន ១០១លើក ប្រជាពលរដ្ឋចូលរួមចំនួន ២ ១២៨នាក់ ស្ត្រី ៧១១នាក់។

# កម្រងរូបភាពសកម្មភាពការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព















# ២. សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ ២០២៤

## គ. ការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ

- គាំទ្រសកម្មភាពអភិវឌ្ឍន៍ភូមិចម្រុះចំនួន **៨ភូមិ** ដោយបានជីកស្រះគ្រួសារចំនួន **៥០ស្រះ**, ផ្តល់កូនឈើហូបផ្លែចម្រុះចំនួន **២ ៨០០ដើម** និងពូជបន្លែចម្រុះចំនួន **១១ ០០០កញ្ចប់** ដល់ **៦៤០គ្រួសារ**
- ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) ដោយបានបណ្តុះបណ្តាលស្តីពី “**ការរៀបចំផែនសកម្មភាពអភិវឌ្ឍភូមិ**” ចំនួន **៤០វគ្គ** មានសិក្ខាកាម **៨០០នាក់** ស្រី **២៥៩នាក់** ក្នុងភូមិគោលដៅចំនួន **២៣៦ភូមិ**
- ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ ដោយបានបណ្តុះបណ្តាលស្តីពី “**សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត**” ចំនួន **៩វគ្គ** សិក្ខាកាម **១៨០នាក់** ស្រី **១៣៦នាក់**, ផ្តល់សម្ភារធ្វើរោងជីកំប៉ុស្ត និងផ្តល់ពូជបន្លែចម្រុះចំនួន **៨៦០០កញ្ចប់** សម្រាប់សួនដំណាំគ្រួសារចំនួន **៣១៥គ្រួសារ**
- ការអប់រំក្រៅប្រព័ន្ធដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ដោយបានបណ្តុះបណ្តាលស្តីពី “**ការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងសហគមន៍**” ចំនួន **៨វគ្គ** មានសិក្ខាកាមសរុប **១៦០នាក់** ស្រី **៨៣នាក់**
- ការបង្កើនចំណេះដឹងបំណិនជីវិត ដោយបានបណ្តុះបណ្តាលស្តីពី “ការងារអភិវឌ្ឍ ការដាំដុះ ការចិញ្ចឹម សហគ្រិនភាព” ចំនួន **៥៩វគ្គ** មានសិក្ខាកាមសរុប **១ ៤៤០នាក់** ស្រី **៤៧១នាក់** (មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ នៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺ)។

# កម្រងរូបភាពសកម្មភាពការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ













# ២. សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ ២០២៤

## ឃ. ការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច

- បានចេញលិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចចំនួន ២៥ សហគមន៍
- ផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច នីតិវិធី និងទម្រង់ឯកសារដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច សរុបចំនួន ២០សហគមន៍ មានអ្នកចូលរួមសរុបចំនួន ១ ៣៣៨ នាក់ ស្រ្តី ៥៩៥នាក់
- ប្រជុំវាយតម្លៃកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច សរុបចំនួន ២៣ សហគមន៍ មានអ្នកចូលរួមសរុបចំនួន ១ ៧៤៥ នាក់ ស្រ្តី ៨៧៧នាក់
- ប្រជុំពេញអង្គ ស្តីពីការពិនិត្យ និងអនុម័តលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងសហគមន៍ជនជាតិដើមភាគតិច ចំនួន ៣សហគមន៍ មានអ្នកចូលរួមសរុបចំនួន ៤២៧នាក់ ស្រ្តី ១៩៣នាក់
- រៀបចំទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី៣០ និងលើកទី២០ មានអ្នកចូលរួមសរុបចំនួន ៨២២នាក់ ស្រ្តី ៣៧៤នាក់
- បណ្តុះបណ្តាលពង្រឹងតួនាទីភារកិច្ច រចនាសម្ព័ន្ធ គណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច និងពង្រឹងសមត្ថភាពសហគមន៍ជនជាតិដើមភាគតិច សរុបចំនួន ១០សហគមន៍ មានអ្នកចូលរួមសរុប ចំនួន ៥៣៤នាក់ ស្រ្តី២៤៩នាក់។

# កម្រងរូបភាពសកម្មភាពការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច















# ២. សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ ២០២៤

## ២.២. ការអភិវឌ្ឍ "ភូមិគំរូ"

- ប្រកាសស្ដីពី ការកំណត់លក្ខណៈសម្បត្តិ "ភូមិគំរូ" របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានបណ្តុះបណ្តាលជនបង្គោលស្តីពី វិធីសាស្ត្រចុះប្រមូលទិន្នន័យ ផ្ទៀងផ្ទាត់ និងវាយតម្លៃលក្ខណៈសម្បត្តិភូមិគំរូ ដែលមានការចូលរួមពីមន្ត្រីរាជការនៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្តទាំង២៥ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ សរុប ១២០នាក់ ស្រី ២៤នាក់
- ប្រកាសទទួលស្គាល់ និងប្រគល់វិញ្ញាបនបត្រ "ភូមិគំរូ" ជូន "ភូមិគំរូ" ជ័យលាភីទាំង ៣០ភូមិ របស់ក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ មានអ្នកចូលរួមប្រមាណ ៣៥០នាក់

# ២. សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ ២០២៤

## ២.២. ការអភិវឌ្ឍ “ភូមិគំរូ”

❖ ទទួលស្គាល់ “ភូមិគំរូ” ចំនួន៣០ភូមិ នៅខេត្តគោលដៅចំនួន ០៣ គឺ÷

- ខេត្តតាកែវចំនួន ១០ភូមិ
- ខេត្តកំពង់ស្ពឺចំនួន ១០ភូមិ
- ខេត្តត្បូងឃ្មុំចំនួន ១០ភូមិ












# ២. សមិទ្ធផលសំខាន់ៗ សម្រេចបានក្នុងឆ្នាំ ២០២៤

## ២.២. ការអភិវឌ្ឍ "ភូមិគំរូ"

- កំពុងអភិវឌ្ឍន៍ "**ភូមិគំរូ**" **ចំនួន ៣៨ភូមិ** តាមរយៈគម្រោងកិច្ចសហការពីសាធារណៈរដ្ឋកូរ៉េ
- សហប្រតិបត្តិការយន្តការត្រី-វិស័យ **កសិកម្ម-ទឹក-ជនបទ** សម្រាប់អន្តរាគមន៍រួមគ្នាចំនួន៤ ទីតាំងក្នុងខេត្តគោលដៅរួមមាន ខេត្តតាកែវ កំពង់ចាម សៀមរាប និងខេត្តបាត់ដំបង ព្រមទាំងសិក្សាជ្រើសរើសទីតាំងបន្ថែមផ្សេងទៀត
- សិក្សាជ្រើសរើស "**ភូមិគំរូ**" **ចំនួន ៥០ភូមិ** ដើម្បីអភិវឌ្ឍន៍ជា "**ភូមិគំរូគន្លឹះ**" សម្រាប់ឆ្នាំ២០២៥

# កម្រងរូបភាពពិនិត្យសមិទ្ធផល "ភូមិគំរូ"













# កម្រងរូបភាពពិនិត្យសមិទ្ធផល "ភូមិគំរូ"














# សកម្មភាពចុះផ្ទៀងផ្ទាត់ និងវាយតម្លៃលក្ខណៈសម្បត្តិ “ភូមិគំរូ”



# ថ្នាក់ដឹកនាំប្រជុំពិនិត្យ ពិភាក្សាការងារ និងការទទួលស្គាល់ “ភូមិគំរូ”













# សកម្មភាពការងារត្រី-វិស័យ កសិកម្ម-ទឹក-ជនបទ














# កម្រងរូបភាពសមិទ្ធផលគម្រោងភូមិសន្តិភាព



# កម្រងរូបភាពសមិទ្ធផលគម្រោងភូមិសន្តិភាព








# កម្រងរូបភាពសមិទ្ធផលគម្រោងភូមិចលនាភូមិថ្មី








# ៣. បញ្ហា និងការប្រឈម

## ៣.១. បញ្ហា

- ការអភិវឌ្ឍសហគមន៍ជនបទ កន្លងមកមិនទាន់មានលក្ខណៈប្រមូលផ្តុំ និងគ្រប់ជ្រុងជ្រោយ
- ការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) កន្លងមកគិតតែបរិមាណមិនទាន់ឆ្លើយតបឱ្យមានប្រសិទ្ធភាព
- កង្វះឧបករណ៍បច្ចេកទេស និងសម្ភារឧបទ្ទេសសិក្សា នៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន
- ខ្វះមន្ត្រីជំនាញឥណទាន ដើម្បីគ្រប់គ្រងឥណទានតាមបណ្តាខេត្តគោលដៅ
- ការចូលរួមអនុវត្តនីតិវិធីរបស់អាជ្ញាធរមូលដ្ឋាន ជនជាតិដើមភាគតិច និងស្ថាប័នពាក់ព័ន្ធក្នុងដំណើរការទទួលស្គាល់អត្តសញ្ញាណនៅមានកម្រិត
- សមត្ថភាពគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចមួយចំនួននៅមានកម្រិតក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន

# ៣. បញ្ហា និងការប្រឈម

## ៣.២ ការប្រឈម

- ថវិកាគាំទ្រនូវមានកម្រិត និងការងារមួយចំនួនពិបាកអនុវត្តតាមគោលការណ៍ និងនីតិវិធី
- កិច្ចសហប្រតិបត្តិការ និងដៃគូអភិវឌ្ឍន៍លើការងារពិពិធកម្មសេដ្ឋកិច្ចជនបទនៅមានកម្រិត
- ការធ្វើបច្ចុប្បន្នភាព និងការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) នៅមានកម្រិត
- ថវិកាគាំទ្រសកម្មភាពអភិវឌ្ឍន៍ "ភូមិគំរូ" នូវមានកម្រិត
- ពុំទាន់មានបញ្ជីមុខរបរនៅតំបន់ជនបទ
- ការពង្រឹងសមត្ថភាព និងបណ្តុះបណ្តាលគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចនៅមានកម្រិត
- ការបង្កើនលទ្ធភាពចុះបំពេញការងារនៅតាមភូមិជនជាតិដើមភាគតិចនៅមានកម្រិត។

# ៤. ទិសដៅការដោះស្រាយ

## ៤.១ ពិពិធកម្មសេដ្ឋកិច្ចជនបទ

### ក. ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ

- កសាងសមត្ថភាព និងផ្សព្វផ្សាយវិធីសាស្ត្រសមស្របដល់ប្រជាពលរដ្ឋដើម្បីផ្លាស់ប្ដូរផ្នត់គំនិត និងឥរិយាបទពីទស្សនពឹងផ្អែកលើជំនួយពីខាងក្រៅ ឱ្យមានភាពជាម្ចាស់នៅមូលដ្ឋាន
- ពង្រឹង និងកៀរគរការគាំទ្រ និងសហការពីដៃគូអភិវឌ្ឍន៍លើវិស័យឥណទានជនបទ និងសកម្មភាពបង្កើនប្រាក់ចំណូលផ្សេងៗ
- បំផុស ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋមានការគាំទ្រផលិតផលក្នុងស្រុក។

# ៤. វិធានការដោះស្រាយ

## ៤.១ ពិពិធកម្មសេដ្ឋកិច្ចជនបទ

### ខ. ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព

- ផ្តល់ការបណ្តុះបណ្តាលជំនាញស្រាវជ្រាវសង្គម ឬអង្កេតផ្សេងៗជូនមន្ត្រីរាជការ និងផ្តល់ថវិកា គាំទ្រប្រចាំឆ្នាំសម្រាប់ការងារសិក្សាស្រាវជ្រាវផ្សេងៗ
- ជំរុញបង្កើត និង/ ឬសហប្រតិបត្តិការជាមួយដៃគូ និងគ្រប់ភាគីពាក់ព័ន្ធរៀបចំទម្រង់នៃការ បណ្តុះបណ្តាលពីចម្ងាយ និង/ ឬតាមប្រព័ន្ធព័ត៌មានវិទ្យា (E-Learning Platform) ដើម្បីសម្រួលដល់មន្ត្រីបានសិក្សាជាប្រចាំ
- សហការជាមួយក្រុមការងារបដិវត្តកម្មឌីជីថលក្រសួងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តុះបណ្តាលតាមប្រព័ន្ធព័ត៌មានវិទ្យា
- សិក្សាសមិទ្ធិលទ្ធភាពរៀបចំគម្រោងសាងសង់អគារមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តឱ្យសមស្រប ទៅនឹងទំហំការងារ និងតម្រូវការជាក់ស្តែង
- បង្កើនថវិកាគាំទ្រប្រចាំឆ្នាំយ៉ាងតិច ១០% (៨០លាន ទៅ១០០លាន/ ឆ្នាំ) នៃទំហំថវិកាបច្ចុប្បន្ន។

# ៤. វិធានការដោះស្រាយ

## គ. ការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ

- បង្កើនថវិកាសម្រាប់ការងារអភិវឌ្ឍន៍សហគមន៍ជនបទ និងចលនាភូមិគំរូ
- បន្តធ្វើបច្ចុប្បន្នភាព និងពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ( គ. អ. ភ)
- មន្ទីអភិវឌ្ឍន៍ជនបទរាជធានី- ខេត្ត វិភាជន៍ថវិកាសម្រាប់ការងារអភិវឌ្ឍន៍សហគមន៍
- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី- ខេត្ត ត្រូវបន្តខិតខំស្វែងរកកិច្ចសហការពីគម្រោងកម្មវិធី និងអង្គការដៃគូនានា ដើម្បីគាំទ្រការធ្វើបច្ចុប្បន្នភាព និងពង្រឹងសមត្ថភាព គ. អ. ភ
- ស្វែងរកកិច្ចសហការ គាំទ្រពីគម្រោងកម្មវិធី និងអង្គការនានាក្នុងការជំរុញចលនា និងសកម្មភាពអភិវឌ្ឍន៍ភូមិគំរូ។

## ៤. ទិសដៅការដោះស្រាយ

### ឃ. ការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច

- បង្កើតក្រុមការងារដើម្បីសម្របសម្រួលជាមួយអង្គការដៃគូ និងភាគីពាក់ព័ន្ធ និងរៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់ដើម្បីស្វែងរកកិច្ចសហការនិងការគាំទ្រផ្សេងៗ
- ផ្សព្វផ្សាយបន្ថែមអំពីសារប្រយោជន៍ដែលទទួលបានអត្តសញ្ញាណ តាមរយៈកិច្ចប្រជុំ សិក្ខាសាលា ឬវគ្គបណ្ដុះបណ្ដាល
- ទំនាក់ទំនង និងពិភាក្សាជាមួយសហគមន៍មូលដ្ឋាន និងមន្ទីរសាមី ដើម្បីរៀបចំប្រតិទិនរដូវកាលសម្រាប់សហគមន៍មូលដ្ឋាន
- បង្កើតវគ្គសិក្ខាសាលា ឬបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពបន្ថែមដល់មន្ត្រីជំនាញ នាយកដ្ឋាន និងមន្ទីរអភិវឌ្ឍន៍ជនបទទាំង១៥ ខេត្តគោលដៅ

# ៥. មេរៀន និងបទពិសោធន៍

## ៥.១. ចំណុចខ្លាំង

ការអភិវឌ្ឍអនុលោមតាមគោលនយោបាយ និងចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយបទដ្ឋាន និងយុទ្ធសាស្រ្តអភិវឌ្ឍន៍ច្បាស់លាស់ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ រួមមាន÷

- យុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដែលមានចក្ខុវិស័យប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០
- ចក្ខុវិស័យរយៈពេល ០៥ឆ្នាំ (២០២៤-២០២៨) របស់ក្រសួងអភិវឌ្ឍន៍ជនបទ គឺ “កសាងតំបន់ជនបទកម្ពុជាប្រកបដោយវិបុលភាព, បរិយាបន្ន, នវានុវត្តន៍, ឌីជីថល, ភាពធន់ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌” ធានាបាននូវប្រាក់ចំណូលគ្រួសារប្រកបដោយចីរភាព និងមានសុខមាលភាពកាន់តែប្រសើរឡើង
- ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទ រយៈពេល ៥ឆ្នាំ(២០២៤-២០២៨)
- កិច្ចសហប្រតិបត្តិការល្អ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដែលធ្វើឱ្យការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល
- ការចូលរួមយ៉ាងសកម្មពីសំណាក់ថ្នាក់ដឹកនាំក្រសួង មន្ត្រីគ្រប់ជាន់ថ្នាក់ អាជ្ញាធរដែនដី គ្រប់ភាគីពាក់ព័ន្ធ និងប្រជាពលរដ្ឋនៅសហគមន៍

# ៥. មេរៀន និងបទពិសោធន៍

## ៥.២. ចំណុចខ្វះខាត

- ធនធានថវិកាសម្រាប់ការគាំទ្រសកម្មភាពពិធិធកម្មសកម្មភាពសេដ្ឋកិច្ច និងភូមិគំរូនៅមានកម្រិត
- លំហូរថវិកាមិនឆ្លើយតបទៅពេលវេលា និងតម្រូវការនៃការអនុវត្ត
- សមត្ថភាពរបស់គណៈកម្មការធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) ប្រជាពលរដ្ឋ និងសហគមន៍ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងការអនុវត្តនៅមានកម្រិត
- ការចូលរួមរបស់យុវជននៅកម្រិតទាប ដោយការធ្វើចំណាក់ ដើម្បីស្វែងរកឱកាសទទួលបានសិក្សា និងការងារនៅទីក្រុង និងក្រៅប្រទេសធ្វើឱ្យខ្វះខាតកម្លាំងពលកម្មនៅតំបន់ជនបទ ដែលជាឧបសគ្គក្នុងការអភិវឌ្ឍនៅមូលដ្ឋាន។

# ៥. មេរៀន និងបទពិសោធន៍

## ៥.៣. សំណូមពរ

- បន្តបង្កើនថវិការ និងប្រសិទ្ធភាពការធ្វើពិពិធកម្មនៅតំបន់សេដ្ឋកិច្ចជនបទ
- បន្តបង្កើនការយកចិត្តទុកដាក់បណ្តុះបណ្តាលជំនាញមូលដ្ឋាន បំណិនជីវិត និងជំនាញវិជ្ជាជីវៈ
- បន្តគាំទ្រដល់ការអភិវឌ្ឍ "**ភូមិគំរូ**" និង "**ភូមិគំរូគន្លឹះ**" ដែលជាយន្តការក្នុងការអន្តរាគមន៍ដោយផ្ទាល់ថ្នាក់ភូមិ និងគ្រួសារ ដែលមានប្រសិទ្ធភាព និងឆ្លើយតបនឹងតម្រូវការជាមូលដ្ឋានរបស់ប្រជាជននៅតំបន់ជនបទ ក្នុងការលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅឱ្យប្រសើរឡើងប្រកបដោយ បរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- លើកកម្ពស់ការរក្សាតុល្យភាពនៃការអភិវឌ្ឍ និងអភិរក្សវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដូនតាល្អៗ ជាពិសេសជនជាតិដើមភាគតិច
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពប្រចាំឆ្នាំ (លំហូរថវិកាឱ្យសមស្របទៅនឹងតម្រូវការ និងពេលនៃការអនុវត្ត)

# ៦. ទិសដៅការងារបន្ត

- បន្តបង្កើនសកម្មភាពធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ បណ្តុះបណ្តាលជំនាញ និងបង្កើតមុខរបរ
- បន្តគាំទ្រប្រសិទ្ធភាពសកម្មភាពអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច
- បន្តគាំទ្រនិរន្តរភាពនៃការអភិវឌ្ឍ "**ភូមិគំរូ**" **ទាំង ៣០ភូមិ** ដែលបានផ្តល់វិញ្ញាបនបត្រទទួលស្គាល់ជា "**ភូមិគំរូ**" ក្នុងឆ្នាំ២០២៤
- តម្រង់ទិសការអភិវឌ្ឍ "**ភូមិគំរូ**" ទាំង **៣៨ភូមិ** ឱ្យក្លាយជា "**ភូមិគំរូ**" ឬ "**ភូមិគំរូគន្លឹះ**"
- អភិវឌ្ឍន៍តាមយុទ្ធសាស្ត្រីកសាយ ដោយជ្រើសរើសយក "**ភូមិគំរូគន្លឹះ**" **ចំនួន ២០០ភូមិ** ដែលមានសក្តានុពលអាចផ្តល់ផលប្រយោជន៍ដល់បណ្តាភូមិនានា (២០២៥-២០២៨)

## ៦. ទិសដៅការងារបន្ត

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាបន្ថែមទៀត ដើម្បីគាំទ្រការអភិវឌ្ឍជា **“ភូមិគំរូគន្លឹះ” ទាំង ២០០ភូមិ** ដូចដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរយៈពេល ៥ឆ្នាំ (២០២៤-២០២៨)
- ខិតខំបន្តកិច្ចសហការឱ្យកាន់តែសកម្មបន្ថែមទៀត ជាមួយបណ្ដាក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីជំរុញនូវសហថាមពលនៃការអភិវឌ្ឍ “ភូមិគំរូ” ឱ្យកាន់តែមានប្រសិទ្ធភាព ប្រកបដោយបរិយាបន្ន។

# ៧. សន្និដ្ឋាន

- ពិពិធកម្មសេដ្ឋកិច្ចជនបទ ដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ បង្កើនប្រាក់ចំណូលគ្រួសារ បង្កើតឱកាសការងារនៅនឹងកន្លែង ដើម្បីកាត់បន្ថយចំណាកស្រុកប្រថុយប្រថាន
- ការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍ **“ភូមិគំរូ”**
- ការអភិវឌ្ឍ **“ភូមិគំរូ”** ជាយន្តការគន្លឹះអភិវឌ្ឍន៍ប្រកដប្រជា និងគ្រប់ជ្រុងជ្រោយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីរួមចំណែកគាំទ្រយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា និងធ្វើឱ្យសម្រេចបានចក្ខុវិស័យប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០
- បង្កើនភាពជាអ្នកដឹកនាំ និងមានតម្លាភាពរបស់សហគមន៍ គឺជាកម្លាំងចលករដែលជំរុញឱ្យភូមិមានភាពរីកចម្រើនកាន់តែលឿន និងធ្វើឱ្យការអភិវឌ្ឍមាននិរន្តរភាព
- បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋក្នុងភាពជាម្ចាស់ និងចេះគិតគូរពីផលប្រយោជន៍សហគមន៍ ធ្វើឱ្យការអភិវឌ្ឍភូមិមានប្រសិទ្ធភាព និងមាននិរន្តរភាព៕

# សំណួរ និងចម្លើយ













# សូមអរគុណ